ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរទន្លេសាប

លេខ : ៦១២ អទស

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពក្រុមការងារទទួលបន្ទុកការអនុវត្តគម្រោង ក្រោមកិច្ចសហប្រតិបត្តិការជាមួយសាធារណរដ្ឋប្រជាមានិតចិន

## ប្រធានអាជ្ញាធរទន្លេសាប

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៤ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប
- បានឃើញសេចក្តីសម្រេចលេខ១៦៣ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០២៥ ស្តីពីការបង្កើតក្រុមការងារទទួលបន្ទុកការអនុវត្តគម្រោងក្រោមកិច្ចសហប្រតិបត្តិការជាមួយសាធារណរដ្ឋប្រជាមានិតចិន
- យោងតាមការចាំបាច់របស់អាជ្ញាធរទន្លេសាប។

អគារលេខ ៥៧៦, ផ្លូវជាតិលេខ ២, សង្កាត់ ចាក់អង្រែក្រោម, ខណ្ឌ មានជ័យ, រាជធានីភ្នំពេញ, ទូរស័ព្ទ / ទូរសារលេខ: (៨៥៥) ២៣ ៧២៧ ៤៥៤
#576, National Road No.2, Sangkat Chak Angre Krom, Khan Meanchey, Phnom Penh, Cambodia, Phone / Fax : (855) 23 727 454, Website: www.tonlesap.gov.kh

# **សម្រេច**

**ប្រការ ១._**

ត្រូវបានកែសម្រួលសមាសភាពក្រុមការងារទទួលបន្ទុកការអនុវត្តគម្រោង ក្រោមកិច្ចសហប្រតិបត្តិការ ជាមួយសាធារណរដ្ឋប្រជាមានិតចិន មានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្តម | **ម៉ៅ** | **ហាក់** | អនុប្រធាន អាជ្ញាធរទន្លេសាប | ប្រធាន |
| ២- ឯកឧត្តម | **ជា** | **សុខនី** | អគ្គលេខាធិការរង អាជ្ញាធរទន្លេសាប | អនុប្រធាន |
| ៣- លោក | **យ៉ាន់** | **សំរិទ្ធ** | ប្រធាននាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ | សមាជិក |
| ៤- លោក | **ទិន** | **ម៉ុនពៅ** | ប្រធាននាយកដ្ឋានធនធានធម្មជាតិ | សមាជិក |
| ៥- លោក | **អ៊ឹម** | **បញ្ញាវឌ្ឍន៍** | ប្រធានការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល | សមាជិក |
| ៦- លោក | **សុខ** | **មុនី** | ប្រធានការិយាល័យនីតិកម្ម | សមាជិក |
| ៧- លោក | **អុល** | **សុជាតិ** | ប្រធានការិយាល័យសម្របសម្រួលវិវាទ | សមាជិក |
| ៨- លោក | **ឡុញ** | **ណារិន្ទ** | ប្រធានការិយាល័យកសិកម្មចម្រុះ | សមាជិក |
| ៩- លោក | **ម៉ម** | **សុធា** | ប្រធានការិយាល័យជីវចម្រុះ | សមាជិក |
| ១០- លោក | **លួច** | **គឹមលុយ** | អនុប្រធានការិយាល័យសម្របសម្រួលវិវាទ | សមាជិក |
| ១១- លោក | **ពុំ** | **រស្មី** | អនុប្រធានការិយាល័យសម្របសម្រួលវិវាទ | សមាជិក |

**ប្រការ ២._**

ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម៖

- ធ្វើការសម្របសម្រួល ដើម្បីធានាឱ្យមានសង្គតភាព រវាងគម្រោងដែលទទួលបានពីដៃគូអភិវឌ្ឍន៍ ក្រោមហិរញ្ញប្បទាននៃសាធារណរដ្ឋប្រជាមានិតចិន និងមេគង្គ-ឡានឆាង និងបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប
- ពិនិត្យ និងសិក្សាលម្អិតរបស់គម្រោង/កម្មវិធី ដូចជា សិក្សាសមិទ្ធិលទ្ធភាព គម្រោងប្លង់លម្អិត មុខទំនិញ លក្ខខណ្ឌការងារ បញ្ជីប៉ាន់ស្មានតម្លៃ ដើម្បីគោរពជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច
- ពិនិត្យ តាមដាន វាយតម្លៃលើដំណើរការនៃការអនុវត្តគម្រោង ដើម្បីធានាបាននូវគុណភាព ប្រសិទ្ធភាព និងការអនុវត្តការងារ ស្របតាមផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប
- ពិនិត្យ និងលើកយោបល់លើរាល់ការចុះអនុស្សរណៈយោគយល់គ្នា កិច្ចសន្យា ឬកែប្រែកិច្ចសន្យា
- រៀបចំ ផែនការកិច្ចសហប្រតិបត្តិការ បណ្តុះបណ្តាល និងថវិកាអនុវត្តគម្រោង/កម្មវិធី
- ធ្វើការត្រួតពិនិត្យ តាមដាន ថែទាំឧបករណ៍ សម្ភារៈ ប្រមូលព័ត៌មាន និងគ្រប់គ្រងទិន្នន័យព័ត៌មានទាំងអស់ជាប្រចាំរបស់គម្រោង/កម្មវិធី
- រៀបចំ និងត្រួតពិនិត្យរបាយការណ៍វឌ្ឍនភាពគម្រោង/កម្មវិធី របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ផ្សេងៗទៀតប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពគម្រោង ការអនុវត្ត និងផលប៉ះពាល់ ដើម្បីកំណត់បញ្ហាប្រឈម និងចំណុចសម្រាប់ការកែលម្អ
- ធានាឱ្យគម្រោង/កម្មវិធីទាំងអស់អនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- រៀបចំលិខិត និងឯកសារសម្រាប់ការប្រគល់-ទទួលរាល់ឧបករណ៍ សម្ភារ រថយន្ត និងគ្រឿងចក្រពេលគម្រោង/កម្មវិធីបញ្ចប់
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ ៣ ._**

ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទអាជ្ញាធរទន្លេសាប ឱ្យជួយការងារតាមការចាំបាច់។

**ប្រការ ៤ ._**

បទប្បញ្ញតិទាំងឡាយណា ដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥ ._**

អនុប្រធានអាជ្ញាធរទន្លេសាប អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានគ្រប់នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ១២ រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០២៥

**ប្រធាន**

ថោ-ជេដ្ឋា

**ចម្លងជូន ៖** ៩

- ក្រសួងធនធានទឹក និងឧតុនិយម
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ